# ប្រាសាទនៈខនហ្លួង៖ ស្ថាបត្យកម្មថៃចុងសម័យអយុធ្យា ដែលមានទំនាក់ទំនងនឹងតំបន់អង្គរ

អយុធ្យាជារដ្ឋអំណាចថ្មីមួយដែលចាប់ផ្ដើមមានអំណាចនិងពង្រីកឥទ្ធិពលរបស់ខ្លួននៅរវាងស.វទី១៤។ មេដឹកនាំអយុធ្យាជាច្រើនសម័យកាលតែងមានទំនាក់ទំនងយ៉ាងច្រើនជាមួយរាជធានីអង្គរតាំងពីដើមសម័យអយុធ្យារហូតដល់ចុងសម័យអយុធ្យា ពោលគឺអយុធ្យាតែងមានការប្រស្រ័យទាក់ទងនិងដឹងឮអំពីអង្គរមិនដែលដាច់ឡើយ។[១] អត្ថបទនេះខ្ញុំនឹងលើយកឧទាហរណ៍ដ៏គួរឱ្យចាប់អារម្មណ៍មួយមកបង្ហាញគឺ សំណង់ប្រាសាទនៈខនហ្លួងដែលជាសំណង់មួយដែលស្ដេចថៃនៅចុងសម័យអយុធ្យា រវាងដើមស.វទី១៧ បានបញ្ជាឱ្យមន្ត្រីរបស់ខ្លួនធ្វើដំណើរមកកាន់តំបន់អង្គរដើម្បីមកចម្លងគំរូប្រាសាទយកទៅសាងប្រាសាទនៅអយុធ្យា។

ប្រាសាទនៈខនហ្លួង ឬអាចជាសំនៀងខ្មែរថា "ប្រាសាទនគរហ្លួង" បច្ចុប្បន្នមានទីតាំងស្ថិតនៅក្នុងឃុំនៈខនហ្លួង ស្រុកនៈខនហ្លួង ខេត្តអយុធ្យា ប្រទេសថៃ។ ប្រាសាទនេះជាសំណង់ធ្វើអំពីឥដ្ឋ បែរមុខទៅទិសខាងជើងតម្រង់ទៅរកទន្លេប៉ាស័ក(ព្រែសក់) សាងឡើងនៅចុងសម័យអយុធ្យា ក្នុងរជ្ជកាលសម្ដេចព្រះចៅប្រាសាទថង (គ.ស.១៦២៩-១៦៥៦)។ តាមរយៈព្រះរាជពង្សាវតាររបស់ថៃជាច្រើនច្បាប់ដូចជាព្រះរាជពង្សាវតារច្បាប់ផ័នចន្ទនុមាស (ចើម) (พันจันทนุมาศ) ព្រះរាជពង្សាវតារច្បាប់សម្ដេចព្រះពនរត្នវត្តព្រះជេតពន បានឱ្យព័ត៌មានដូចគ្នាថា នៅឆ្នាំ១៦៣១ សម្ដេចព្រះចៅប្រាសាទថងបានបញ្ជាឱ្យជាងទៅចម្លងបែប "ព្រះនគរហ្លួង" ក្រុងកម្ពុជាដើម្បីធ្វើជាវាំងសម្រាប់ប្រថាប់សម្រាកពេលធ្វើដំណើរទៅនមស្ការព្រះពុទ្ធបាទនៅខេត្តសរៈបុរី។[២] ព័ត៌មានលម្អិតក្នុងពង្សាវតារច្បាប់សម្ដេចព្រះពនរត្នវត្តព្រះជេតពនមានសេចក្ដីថា "...លុះ(ចុល)សករាជ ៩៩៣ ឆ្នាំមមែ ត្រីសក ទ្រង់ព្រះករុណាឱ្យជាងចេញទៅចម្លងបែបព្រះនគរហ្លួងនិង

---

[១] សូមអាន៖ ศานติ ภักดีคำ 2020: 30-139.

[២] คณะกรรมการฝ่ายประมวลเอกสารและจดหมายเหตุ 1999: 379.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

ប្រាសាទក្រុងកម្ពុជប្រទេសយកមកឱ្យជាងធ្វើព្រះរាជវាំង ជាទីប្រថាប់សម្រាក(នៅ)តំបន់វត្តទេពចន្ទ សម្រាប់ឡើងទៅនមស្ការព្រះពុទ្ធបាទ ទើបយកនាមដើមដែលចម្លងមកប្រើឈ្មោះថា ព្រះនគរហ្លួង...” ។[៧] ពាក្យថា “ហ្លួង” នៅក្នុងភាសាថៃក្រៅពីមានន័យថា “ជារបស់ព្រះរាជា” ពាក្យនេះអាចមានន័យមួយទៀតថា “ជាធំ” ដែរ។[៨] ដូចនេះនគរហ្លួង ក៏អាចសំដៅ “នគរធំ” ឬបច្ចុប្បន្នខ្មែរយើងហៅថា “អង្គរធំ” នោះឯង។

បើយើងសង្កេតទៅលើលក្ខណៈប្លង់ទូទៅរបស់ប្រាសាទនគរហ្លួងវិញឃើញថា មានលក្ខណៈត្រូវគ្នានឹងប្លង់ប្រាសាទអង្គរវត្ត ពោលគឺជាសំណង់មានខឿន៣ជាន់លើកខ្ពស់ពីដីនៅលើជាន់នីមួយៗនៃខឿនមានធ្វើជារបៀងឬថែវព័ទ្ធជុំវិញ(រូបលេខ១)។




រូបលេខ១៖ រូបខាងឆ្វេង ប្រាសាទនៈខនហ្លួង និងរូបខាងស្តាំ ប្រាសាទអង្គរ មើលពីលើ

(រូបថត៖ Google Maps)

[៧] ศานติ ภักดีคำ 2015: 186.

[៨] ราชบัณฑิตยสถาน 2013: 1311-1312.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

នៅតាមមុមនិងតាមទិសធំនៃរបៀង មានធ្វើជាកំពូលប្រាសាទប្រចាំមុមនិងប្រចាំទិសធំទាំងបួន(រូបលេខ២២)។ អ្វីដែលគួឱ្យចាប់រម្មណ៍ជាងនេះទៅទៀតគឺ ការព្យាយាមធ្វើអគារភ្ជាប់របៀងជាន់ទី១និងរបៀងជាន់ទី២នៅផ្នែកខាងត្បូង លក្ខណៈនេះស្រដៀងគ្នានឹងរូតព្រះពាន់នៃប្រាសាទអង្គរវត្ត តែខុសគ្នាបន្តិចត្រង់មិនធ្វើឱ្យជាប់គ្នាជិតដូចប្រាសាទអង្គរទេ (រូបលេខ២៣)។



រូបលេខ២២៖ ប្រាសាទនៈខនហ្លួង មើលពីទិសខាងជើង (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ២៣៖ អគារភ្ជាប់របៀងជាន់ទី១និងរបៀងជាន់ទី២ នៅផ្នែកខាងត្បូង (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

លក្ខណៈសំណង់របៀងជាន់ទី១និងទី២ ជាសំណង់ដែលសល់តាំងពីការកសាងនៅយុគដំបូងៗ តែសម្រាប់របៀងជាន់លើបង្អស់ជាសំណង់ដែរជួសជុលឡើងវិញនៅសម័យរតនកោសិន្ទ្ររាវងស.វទី១៩។ នៅតាមជញ្ជាំងផ្នែកខាងក្រៅនៃរបៀងជាន់ទី១និងជាន់ទី២ មានលម្អសសរផ្អោប ហើយនៅចន្លោះសសរផ្អោបនោះមានធ្វើជាចម្រឹងបង្អួចបញ្ឆោត (រូបលេខ៤) ដែលលក្ខណៈនេះជាការធ្វើត្រាប់តាមចម្រឹងបង្អួចនៃប្រាសាទអង្គរវត្ត។[៥]



រូបលេខ៤៖ របៀងជាន់ទី១ និងជញ្ជាំងខាងក្រៅនៃរបៀងជាន់ទី២ (រូបថត៖ ឡេង ស៊ីវ៉ង់)

ចំពោះរបៀងជាន់ទី៣វិញ សំណង់ដែលសល់តាំងពីការកសាងពីដំបូងមានតែខឿនតែប៉ុណ្ណោះ ដោយឡែកតួរបៀងវិញជាសំណង់ថ្មីដែលសាងឡើងនៅសម័យស្តេចរាមាទី៥ (១៨៥៣-១៩១០) ហេតុនេះហើយបានជានៅតាមមុមទាំង៤និងទិសធំទាំង៤នៃរបៀងមានលក្ខណៈជាកំពូលជាចេតិយខុសពីរបៀងជាន់ទី១និងទី២ដែលជាកំពូលប្រាសាទ (រូបលេខ៥)។

---

[៥] ศักดิ์ชัย สายสิงห์ 2021: 340.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ២៥៖ របៀងជាន់ទី៣ មើលពីទិសពាយព្យ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ២៦៖ មណ្ឌបនៅជាន់លើបង្អស់
(រូបថត៖ ឡេង ស៊ីវ៉ង់)

នៅចំណុចកណ្តាលនៃជាន់លើបង្អស់បច្ចុប្បន្នជាមណ្ឌបមានបង្វង់រាងកាកបាទ (រូបលេខ២៦) ខាងក្នុងតម្កល់ព្រះពុទ្ធបាទ៤ព្រះអង្គ។ ក្នុងចំណោមអ្នកស្រាវជ្រាវថៃយល់ថា សំណង់ផ្នែកកណ្តាលនេះ ពីដើមប្រហែលជាសំណង់ឈើ ហើយក្រោយមកត្រូវគេកែប្រែឱ្យទៅវិហារដែលមាននាទីជារោងឧបោសថនៅឆ្នាំ១៨០៩ដោយព្រះភិក្ខុនាមពិន មុននឹងត្រូវកែប្រែម្តងទៀតឱ្យក្លាយជាមណ្ឌបដូចសព្វថ្ងៃនេះ។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

បើទោះបីជាអ្នកជំនាញថៃភាគច្រើនមានការយល់ឃើញស្របគ្នាថាប្រាសាទនៈខនហ្លួងនេះជាសំណង់ដែលបានគំរូប្លង់ពីប្រាសាទអង្គរវត្តក៏ពិតមែន តែក៏មានអ្នកស្រាវជ្រាវខ្លះយល់ឃើញខុសពីនេះដែរ។ ការដែលសំណង់ប្រាសាទនៈខនហ្លួងមានកំពូលច្រើននៅតាមរបៀងនៃជាន់នីមួយៗបែបនេះ ធ្វើឱ្យអ្នកស្រាវជ្រាវមួយចំនួនយល់ថាសំណង់នេះអាចយកគំរូប្លង់តាមប្រាសាទបាពួនជាង ព្រោះប្រាសាទបាពួនជាស្ថាបត្យកម្មមានខឿន៣ជាន់ មានរបៀងតាមជាន់នីមួយៗ ជាពិសេសមានកំពូលប្រាង្គសរុប២៩ដូចគ្នានិងប្រាសាទនៈខនហ្លួន(រូបលេខ៧)។[៦]



រូបលេខ៧៖ ប្រាសាទបាពួន មើលពីទិសខាងកើត (រូបថត៖ AMS Central)

សរុបមកបើទោះបីជាមានការពិភាក្សា និងយល់ឃើញផ្សេងគ្នាពីសំណាក់អ្នកស្រាវជ្រាវថៃអំពីគំរូបប្លង់ប្រាសាទនៅតំបន់អង្គរដែលមានឥទ្ធិពលទៅលើប្រាសាទនៈខនហ្លួងក៏ដោយ ក៏អ្នកស្រាវជ្រាវទាំងនោះមានគំនិតរួមគ្នាមួយដែរថា ប្រាសាទនៈខនហ្លួងពិតជាបានទទួលឥទ្ធិពលពីប្លង់ប្រាសាទណាមួយនៅតំបន់អង្គរ ដូចមានរៀបរាប់នៅក្នុងពង្សាវតារជាច្រើនច្បាប់របស់ថៃអំពីការបញ្ជូនជាងទៅចម្លងបែបព្រះនគរហ្លួងនិងប្រាសាទក្រុងកម្ពុជប្រទេស៕

[៦] เกรียงไกร เกิดศิริ และคณะ 2018: 71-90.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

# បញ្ជីឯកសារយោង

เกรียงไกร เกิดศิริ และคณะ

2018. ปราสาทนครหลวง อยุธยา (*ប្រាសាទនៈខនហ្លួង អយុធ្យា*). วรสารหน้าจั่ว, 33 (มกราคม-ธันวาคม), A71-A90. https://so04.tci-thaijo.org/index.php/NAJUA-Arch/article/view/150764/110402

คณะกรรมการฝ่ายประมวลเอกสารและจดหมายเหตุ

1999. พระราชพงศาวดารกรุงศรีอยุธยา ฉบับพันจันนุมาศ (เจิม) (*ព្រះរាជពង្សាវតារ ក្រុងស្រីអយុធ្យា ច្បាប់ផ័នចន្ទនុមាស (ចើម)*), ใน ประชุมพงศาวดารฉบับกาญจนาภิเษก เล่มที่ 3. กรุงเทพฯ.

ราชบัณฑิตยสถาน

2013. พจนานุกรมฉบับราชบัญฑิตยสถาน พ.ศ. 2554 (*វចនានុក្រម ច្បាប់រាជបណ្ឌិត្យស្ថាន គ.ស.២០១១*), กรุงเทพฯ ราชบัญฑิตยสถาน.

ศักดิ์ชัย สายสิงห์

2021. คู่มือนำชม ศิลปกรรมโบราณในอยุธยา (*សៀវភៅមគ្គុទេស សិល្បកម្មបូរាណក្នុងអយុធ្យា*), นนทบุรี, เมืองโบราณ.

ศานติ ภักดีคำ

2020. นครวัดทัศนะสยาม (*នគរវត្តទស្សនៈសៀម*), กรุงเทพฯ, มติชน.

2015. บรรณาธิการและตรวจสอบชำระ, พระราชพงศาวดารฉบับสมเด็จพระพนรัตน์ วัดพระเชตุพนฯ(*ព្រះរាជពង្សាវតារ ច្បាប់សម្ដេចព្រះពនរត្នវត្តព្រះជេតពន*), พรุงเทพฯ , อมรินทร์.

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់